**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

**សារលិខិតជូនពរ**

**សូមគោរពជូន**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

**សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី ជាទីគោរពដ៏ខ្ពង់ខ្ពស់!**

យើងខ្ញុំទាំងអស់គ្នាជាថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិកនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ សូមអនុញ្ញាតសម្តែងនូវអំណរសាទរ និង មនោសញ្ចេតនារំភើបសប្បាយរីករាយយ៉ាងក្រៃលែងក្នុងឱកាសថ្ងៃខួបកំណើត **សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** គម្រប់៦៤ ឈានចូល ៦៥ឆ្នាំ ត្រូវនឹងថ្ងៃទី៥ ខែសីហា ឆ្នាំ២០១៥ ។ ក្នុងឱកាសដ៏ថ្លៃថ្លានេះ យើងខ្ញុំសូមគោរពជូនពរ **សម្តេចអគ្គមហាសេនាបតីតេជោ** សូមមានជន្មាយុយឺនយូរ សុខភាពល្អបរិបូណ៌ ប្រាជ្ញាឆ្លាសវៃ ដើម្បីសម្រេចបានជោគជ័យថ្មីៗថែមទៀតក្នុងការដឹកនាំរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

ក្នុងទិវាដ៏មហាប្រសើរនេះ យើងខ្ញុំសូមសម្តែងនូវការដឹងគុណដ៏ជ្រាលជ្រៅ និង សូមកោតសរសើរដោយស្មោះចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** នូវមគ្គុទ្ទេសក៏ភាពដ៏ប៉ិនប្រសប់ប្រកបដោយគតិបណ្ឌិតក្នុងការដឹកនាំរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដែលទទួលបានជោគជ័យត្រចះត្រចង់ទាំងកម្រិតជាតិ តំបន់ និង អន្តរជាតិ ធ្វើឱ្យប្រទេសមានសុខសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍន៍គ្រប់វិស័យ ។

ជាថ្មីម្តងទៀត ក្នុងនាមថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការ និង បុគ្គលិកនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ យើងខ្ញុំសូមប្រសិទ្ធពរជ័យសិរីសួស្តី ជ័យមង្គល វិបុលសុខ បវរមហាប្រសើរថ្លៃថ្លាជូន **សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ព្រមទាំង បុត្រាបុត្រី និង ចៅប្រុសចៅស្រី សូមបានប្រកបដោយពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីយើងខ្ញុំ ។

រាជធានីភ្នំពេញ ថ្ងៃទី៥ ខែសីហា ឆ្នាំ២០១៥

**ទេសរដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

**អៀង_មូលី**

អាសយដ្ឋាន: អគារលេខ ១៦ ផ្លូវលេខ ២៧១ កែង ១៥០ សង្កាត់ទឹកល្អក់ II ខណ្ឌទួលគោក រាជធានីភ្នំពេញ ទូរស័ព្ទ / ទូរសារ (៨៥៥-២៣) ៨៨៥ ១២៩